**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមការងារចុះមូលដ្ឋាន**
**ខេត្តក្រចេះ**

**សូមជម្រាបជូន**
**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធាន អនុប្រធាន និងសមាជិកក្រុមការងារ ចុះមូលដ្ឋានស្រុក ក្រុង ឃុំ សង្កាត់ ទូទាំងខេត្តក្រចេះ**

**កម្មវត្ថុ៖** ស្តីពីការចូលរួមបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ នៅតាមវត្តនានា ស្ថិតក្នុងស្រុក ក្រុង ទាំង៦ នៃខេត្តក្រចេះ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធាន អនុប្រធាន និងសមាជិកក្រុមការងារ ស្រុក ក្រុង ឃុំ សង្កាត់ ទូទាំងខេត្តក្រចេះ មេត្តាជ្រាបថា ដើម្បីចូលរួមប្រារព្ធពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌទៅតាមគន្លងប្រពៃណីព្រះពុទ្ធសាសនានៅឆ្នាំនេះ ដែលចាប់ផ្តើមពីថ្ងៃ១រោច ដល់១៥រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា ដល់ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២១ ខ្ញុំសូមអំពាវនាវ ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តារួមសាមគ្គីជាមួយសប្បុរសជន និងពុទ្ធបរិស័ទចំណុះជើងវត្ត ម្ចាស់ការរៀបចំចាត់ចែងពិធីនេះនៅតាមវត្តនានាក្នុងមូលដ្ឋានស្រុក ក្រុង ឃុំ សង្កាត់ រៀងៗខ្លួន។

ចំពោះរូបភាព កម្មវិធី និងកាលបរិច្ឆេទ នៃការប្រារព្ធពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌឆ្នាំនេះ គឺអាស្រ័យដោយការសម្រេចរបស់ក្រុមការងារស្រុក ក្រុង ឃុំ សង្កាត់ នីមួយៗ ដើម្បីធានាសុវត្ថិភាព សុខុមាលភាព ជៀសផុតពីជំងឺកូវីដ-១៩ ដោយត្រូវចាក់វ៉ាក់សាំង និងប្រកាន់ខ្ជាប់នូវវិធានការ "៣ការពារ និង ៣កុំ"។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសប្បុរសជនទាំងអស់ មេត្តាជ្រាប និងចូលរួមពិធីបុណ្យឱ្យបានច្រើនកុះករដើម្បីចាប់មគ្គផល និងទទួលកុសលផលបុណ្យទៅតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសប្បុរសជនទាំងអស់ មេត្តាទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅបំផុតពីខ្ញុំ។ ៗ

ថ្ងៃ សុក្រ ៨ កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០២១
**ប្រធានក្រុមការងារចុះមូលដ្ឋានខេត្តក្រចេះ**

**ហ៊ុំ សុខា**